# រឿងស័ង្គសិល្ប៍ជ័យក្នុងល្ខោនបាសាក់

ល្ខោនបាសាក់ ជាទម្រង់សិល្បៈទស្សនីយភាពមួយ ដែលមានប្រជាប្រិយភាពធំធេងណាស់នៅក្នុងស្រទាប់ទស្សនិកជនខ្មែរ។ ទម្រង់នេះមានវត្តមានរហូតមកដល់ឆ្នាំ១៩៥៣ ឬក្រោយនេះបន្តិច នៅតាមទីជនបទនានា ដូចជាខេត្តកណ្ដាលឬតាមជាយក្រុងភ្នំពេញជាដើម។ ចំណែកឯប្រជាជនខ្មែរដែលរស់នៅភាគខាងក្រោម នៃប្រទេសកម្ពុជា គឺដែនដីកម្ពុជាក្រោមដែលបានក្លាយទៅជាដែនដីភាគខាងត្បូង នៃប្រទេសវៀតណាមនៅឆ្នាំ១៩៤៩ និយមហៅទម្រង់ល្ខោននេះថា «ល្ខោនយូរកេរ» ដែលមានន័យថា «មរតករបស់ខ្មែរ តាំងពីយូរលង់ណាស់មកហើយ»។[១]

ក្នុងអំឡុងឆ្នាំ១៩២៩ ឬ ១៩៣០ ក្រោយពីពេលដែលពង្រីកពង្រឹងខ្លួនរឹងមាំហើយ ក្រុមសិល្បៈយូរកេរនៃស្រុកបាសាក់ដែលដឹកនាំដោយលោក **ឆា គ្រួន** (ឈ្មោះដើម លី សួន) បានធ្វើសកម្មភាពឡើងមកសម្ដែងនៅបណ្ដាខេត្តមួយចំនួនតាមដងទន្លេមេគង្គ និងរាជធានីភ្នំពេញ តាមទូកប៉ុកចាយជាមធ្យោបាយដឹកជញ្ជូន ស្នាក់នៅ និងកន្លែងសម្ដែងខ្លះផង។[២]

ទស្សនិកជននៅដំបន់កម្ពុជាកណ្ដាល ជក់ចិត្តជិតអារម្មណ៍យ៉ាងខ្លាំងរហូតដល់នាំគ្នាហៅទម្រង់ល្ខោននេះថា «ល្ខោនបាសាក់» ដោយយកទីកន្លែងកំណើតនៃវង់សិល្បៈមកដាក់ជាឈ្មោះទម្រង់តែម្ដង រហូតមកទល់នឹងសព្វថ្ងៃនេះ។

ក្រោយពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានបង្កើតឡើងនៅឆ្នាំ១៩៦៥មក ទម្រង់ល្ខោនបាសាក់ក៏ដូចជាទម្រង់សិល្បៈឯទៀត ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សកលវិទ្យាល័យ ដោយមានការចាត់ឱ្យគ្រូនិងសិស្សចុះទៅធ្វើការស្រាវជ្រាវ រៀនសូត្រពីគ្រូនិងសិល្បករជំនាញ ដូចជាលោកតា សាំង សារុន និង អ្នកស្រី ចេក ម៉ាច លោកគ្រូ ពៅ លោកគ្រូ ណាន និងលោកគ្រូ សាមិត ជាដើម។ លើសពីនេះទៅទៀត សកលវិទ្យាល័យក៏

[១] ពេជ្រ ទុំក្រវិល ២០០០: ៣៨

[២] ពេជ្រ ទុំក្រវិល ២០០៣: ១៥៧

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

បានអញ្ជើញលោកគ្រូ ទក ខ្មៅ ដែលមានទេពកោសល្យ ខ្ពស់លើតួឯក តួយក្ស និងតួត្លុក មកបង្រៀនសិស្សថែមទៀត។

វង់តន្ត្រីបាសាក់ រួមមានឧបករណ៍ទ្រអ៊ូ (ឧបករណ៍សំខាន់នាំមុខ) ឃឹមតូច ឃឹមធំ ខ្លុយ ប៉ាន់ ឡោ ឃ្មោះ និងស្គរ ដែលមានលក្ខណៈឥទ្ធិពលចិនច្រើន។ «ហួន» ជាលក្ខណៈពិសេស របស់ល្ខោនបាសាក់។ សឹងតែគ្រប់តួអង្គទាំងអស់ មានក្បាច់ហួន ប្រចាំតួរៀងៗខ្លួន ពោលគឺ ហួនប្រុស ហួនស្រី ហួនយក្ស ជាដើម។

ល្ខោនបាសាក់សម្ដែងរឿងជាច្រើនរួមមាន ព្រះលក្សិណាវង្ស ព្រះច័ន្ទគោរព រតនាវង្ស ម៉ាក់កូយុងកែវ និងស័ង្ខសិល្បជ័យ ជាដើម។ល។

**រឿងស័ង្ខសិល្បជ័យ**

រឿងស័ង្ខសិល្បជ័យ ជារឿងបុរាណ ដែលគេទុកជាកម្រងស្នាដៃដ៏ល្បី និងមានកម្រិតខ្ពស់ក្នុងអក្សរសិល្ប៍ខ្មែរ។ ផ្ទាំងរឿងស័ង្ខសិល្បជ័យនេះ លាតត្រដាងពី ទំនាស់រវាងសភាវៈបណ្ឌិតនិងពាល។

កាលនោះ នគរបញ្ចបុរីមានទុរភឹករឹករវ ដោយមានយក្សឃោរឃៅចាប់ប្រជារាស្ត្រ ស៊ីរាល់ថ្ងៃ។ ព្រះចៅក្រុងបញ្ចបុរី មានមហេសីនិងបុត្រជាច្រើនអង្គ។ ថ្ងៃមួយយក្ស កុម្ភ័ណ្ឌ បានចាប់យកនាង កែវ សុមន្ទា ដែលជាអគ្គមហេសីនៃព្រះចៅក្រុងបញ្ចបុរី យកទៅធ្វើជាមហេសីរបស់ខ្លួន។ ព្រះចៅក្រុងបញ្ចបុរី មានសេចក្ដីទោមនស្ស កើតទុក្ខយ៉ាងខ្លាំងដោយព្រាត់ប្រាស់ពីនាង កែវ សុមន្ទា។

ថ្ងៃងពីមហេសីឯទៀត ដោយសេចក្ដីច្រណែនឈ្នានីស មានសេចក្ដីសោមនស្សត្រេកអរជាអនេកដែលនាង កែវ សុមន្ទា ត្រូវបានយក្ស កុម្ភ័ណ្ឌ ចាប់យកទៅបាត់នេះ។ ជាបន្ទាប់មក មហេសីយង់ឃ្នងទាំងនោះ បានចាក់រុកព្រះចៅក្រុងបញ្ចបុរី ឱ្យបំបោះបង់មហេសីមួយអង្គទៀត ដែលបានប្រសូតព្រះរាជបុត្រពីរអង្គ មួយអង្គជា គជសីហ៍ និងមួយ

អង្គទៀត ជាខ្យងស័ង្ខ ដោយចោទថាចង្រៃណាស់។ ដូច្នេះហើយ បានជានគរមានទុរភឹករំកែវរ មានយក្សមកចាប់ប្រជារាស្ត្រស៊ីរាល់ថ្ងៃ។

ថ្ងៃពីបុត្រពាលប្អូនអង្គ បានចូលមកគាល់ព្រះបិតា ហើយធានាថានឹងទៅរំដោះព្រះមាតុឆា ព្រះនាង កែវ សុមន្ទា ដែលកុម្ភ័ណ្ឌបានចាប់យកទៅនោះមកវិញ។ តាមការពិត បុត្រពាលទាំងប្អូនអង្គ មានកលល្បិចចង់សម្លាប់ប្អូនទាំងបី ដោយធ្វើរាជសារក្លែងក្លាយយកទៅឱ្យគជសីហ៍ ខ្យងស័ង្ខ និងស័ង្ខសិល្ប៍ជ័យ ថាជាព្រះរាជសារពីព្រះបិតាព្រះចៅក្រុងបញ្ចបុរី បញ្ជាឱ្យអ្នកទាំងបីទៅរំដោះ ព្រះមាតុឆាពីយក្សកុម្ភ័ណ្ឌទៅវិញ។

ដោយគ្មានក្តីងឿងឆ្ងល់ពីរាជសាររបស់ព្រះបិតា និងដោយគោរពតាមព្រះរាជបញ្ជារបស់ព្រះបិតា គជសីហ៍ ខ្យងស័ង្ខ និងស័ង្ខសិល្ប៍ជ័យ ក៏នាំគ្នាចេញទៅ ស្វែងរកនិងរំដោះព្រះមាតុឆាពីកុម្ភ័ណ្ឌ។ តាមផ្លូវឆ្លងសមុទ្រ បុត្រពាលទាំងប្អូនអង្គ សុំឱ្យគជសីហ៍នៅជាមួយដើម្បីជួយថែរក្សាខ្លួនឯនាយសមុទ្រ។ ចំណែកឯ ស័ង្ខសិល្ប៍ជ័យ ក៏ជិះលើខ្យងស័ង្ខឆ្លងកាត់សមុទ្រទៅនគរកុម្ភ័ណ្ឌ តាមរកព្រះមាតុឆា នាង កែវ សុមន្ទា។ នានគរកុម្ភ័ណ្ឌ កុម្ភ័ណ្ឌបម្រុងនឹងលើកបុត្រី នាងសុពណ៌ទេវី ឱ្យទៅមហារាជ ស្តេចកុជង្គនាគ ក្នុងគោលបំណងចងស្ពានមេត្រីពង្រឹងមិត្តភាព។ នៅពេលដែលកុម្ភ័ណ្ឌ យកនាងសុភណ៌ទេវី ទៅថ្វាយមហារាជនាស្ថានកុជង្គនាគនោះ ស័ង្ខសិល្បជ័យនិង ខ្យងស័ង្ខ ក៏បានមកដល់នគរកុម្ភ័ណ្ឌ ហើយបានជួយនឹងនាង កែវ សុមន្ទា។ កុម្ភ័ណ្ឌ នៅពេលត្រឡប់មកដល់ព្រះនគរវិញ ក៏ត្រូវស័ង្ខសិល្ប៍ជ័យនិងខ្យងស័ង្ខ សម្លាប់ចោលទៅ៕

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង







អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





## ឯកសារយោង


ពេជ្រ, ទុំក្រវិល. (២០០០). *ស្បែកពណ៌និងស្បែកតូច.* ភ្នំពេញ: មូលនិធិតូយ៉ូតា។

ពេជ្រ ទុំក្រវិល. (២០០៣). *ទស្សនីយភាពខ្មែរ.* ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

សំ សំអាង. (៣ ធ្នូ ២០២០). «ល្ខោនបាសាក់,» *បណ្ដាញព័ត៌មានអប្សរា។*


អត្ថបទដោយ៖ បណ្ឌិត សំ សំអាង